រាជរដ្ឋាភិបាលកម្ពុជា

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

# គុណសម្បត្តិ

# នៃ

# ឥរិយាបថរបស់មន្ត្រីរាជការ

ខែមិថុនា ឆ្នាំ២០០៩

# គុណសម្បត្តិ
# នៃ
# ឥរិយាបថរបស់មន្ត្រីរាជការ

ឆន្ទៈម្ចាស់ការ

ភក្ដីភាព

មនសិការវិជ្ជាជីវៈ

វប្បធម៌សេវាសាធារណៈ



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

និងជាប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

# អារម្ភកថា

ប្រទេសកម្ពុជាបានឆ្លងកាត់របត់ប្រវត្តិសាស្ត្រជាច្រើនដំណាក់កាល តាំងពីសម័យអាណានិគមនិយមបារាំងរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ។ ដោយសារការវិវត្តនៃរបបនយោបាយ និងរបបគ្រប់គ្រងប្រទេសជាតិ រដ្ឋបាលសាធារណៈដែលមានតួនាទីបន្តនិរន្តរភាពរបស់រដ្ឋ ក៏ត្រូវមានការវិវត្តទៅតាមរបបនយោបាយគ្រប់ដំណាក់កាលដែរ។ ប៉ុន្តែការវិវត្តដ៏ធំជាងគេ គឺកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៧មេសា ១៩៧៥ ដល់មុន ថ្ងៃ៧ មករា ១៩៧៩) ដោយសាររចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ រួមទាំងរដ្ឋបាលសាធារណៈ ត្រូវបានរំលាយចោលទាំងស្រុង។ ឆ្លងកាត់ដំណាក់កាលទាំងអស់នោះ ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសមន្ត្រីរាជការដែលបម្រើការងាររដ្ឋបាល បានដក

ស្រង់នូវមេរៀនពិសោធជាច្រើនរាប់មិនអស់ ដែលនោះគឺជាទុនដ៏សំខាន់សម្រាប់ការពង្រឹងសមត្ថភាពបុគ្គលនិងស្ថាប័ន។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ក្រសួងស្ថាប័នរដ្ឋ ត្រូវបានរៀបចំបង្កើតឡើងវិញ។ មន្ត្រីរាជការដែលបានចូលបម្រើការងារតាមក្រសួង ស្ថាប័នទាំងអស់គឺសុទ្ធសឹងតែជាអតីតសិស្ស និស្សិត បញ្ញវន្តនិងមន្ត្រីរាជការពីសម័យមុន ដែលនៅសេសសល់ពីការកាប់សម្លាប់ក្នុងរបបប្រល័យពូជសាសន៍។

ដោយឆន្ទៈមោះមុតនិងទឹកចិត្តស្រឡាញ់ប្រទេសជាតិមាតុភូមិ មន្ត្រីរាជការគ្រប់រូប បានខិតខំប្រឹងប្រែងចូលរួមចំណែកយ៉ាងសកម្មក្នុងការស្តារនិងអភិវឌ្ឍប្រទេសជាតិឡើងវិញពីបាតដៃទទេ រហូតដល់មានការរីកចម្រើនជាបន្តបន្ទាប់ពីអាណត្តិមួយ

ទៅអាណត្តិមួយ ក្នុងរយៈពេលមួយដ៏ខ្លីស្ទើរតែមិនគួរឱ្យជឿបាន សម្រាប់អ្នកដែលមិនដែលឃើញ។ ការធ្វើសមាហរណកម្មទៅក្នុងតំបន់និងសកលលោក រួមផ្សំនឹងការខិតខំប្រឹងប្រែងរបស់ជាតិទាំងមូលបានធ្វើឱ្យកម្ពុជាមានលទ្ធភាពជំរុញបាននូវកំណើនសេដ្ឋកិច្ចរបស់ខ្លួនគួរជាទីមោទនភាពក្នុងចរន្តសកលភាវូបនីយកម្ម។

ក្នុងនាមប្រមុខរាជរដ្ឋាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរដោយស្មោះដល់មន្ត្រីរាជការគ្រប់រូប និងសូមលើកទឹកចិត្តយ៉ាងខ្លាំងក្លា ឱ្យបន្តនូវវប្បធមិឧស្សាហ៍ព្យាយាម រៀនផង ធ្វើការផង បន្តលើកកម្ពស់សមត្ថភាពផ្ទាល់ខ្លួននិងស្ថាប័ន ដើម្បីបុព្វហេតុជាតិនិងប្រជាជន។

ខ្ញុំសូមទាញការចាប់អារម្មណ៍ថា រាជរដ្ឋាភិបាលបានប្រកាន់យកនូវការងារកំណែទម្រង់លើគ្រប់វិស័យ

ជាអាទិភាពរបស់ខ្លួន ជាអាទិ៍ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ច្បាប់និងតុលាការនិងកំណែទម្រង់តាមវិស័យដទៃទៀត ដោយប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍អភិបាលកិច្ចល្អជាមូលដ្ឋាន ដើម្បីលើកកម្ពស់កម្រិតនីតិរដ្ឋឱ្យបានកាន់តែរឹងមាំក្នុងចំណោមបណ្តារដ្ឋទំនើបដទៃទៀតនៅលើសកលលោក និងសូមអំពាវនាវឱ្យមន្ត្រីរាជការគ្រប់រូប ចូលរួមឱ្យកាន់តែសកម្មខ្លាំងក្លាថែមទៀត ក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ខាងលើនេះ។

យើងកំពុងតែស្ថិតនៅក្នុងដំណាក់កាលនៃការកែទម្រង់ស៊ីជម្រៅ។ ទន្ទឹមនឹងការខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនយើង ក្នុងរង្វង់ ១%

ក្នុងមួយឆ្នាំ យើងត្រូវខិតខំបង្កើនប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈ ដែលជាបេសកកម្មដ៏ចម្បងក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដើម្បីសុខុមាលភាពរបស់ប្រជាជន និងវិបុលភាពប្រទេសជាតិយើង។

ដើម្បីសម្រេចបានគោលដៅនេះ មន្ត្រីរាជការគ្រប់រូបត្រូវពង្រឹងគុណសម្បត្តិទាំង ៤ យ៉ាងរបស់ខ្លួនឱ្យបានសក្តិសមជាអ្នកផ្តល់សេវាជូនប្រជាពលរដ្ឋ តាមគន្លងនៃអភិបាលកិច្ចល្អ សំដៅលើកកម្ពស់សមត្ថភាពស្ថាប័នឱ្យមានភាពរឹងមាំ ប្រកបដោយនិរន្តរភាព។

ខ្ញុំមានការជឿជាក់ថា កូនសៀវភៅដ៏តូចនេះនឹងក្លាយទៅជាជំនួយស្មារតីប្រចាំខ្លួនមន្ត្រីម្នាក់ៗ សម្រាប់ដាស់តឿនក្រើនរំលឹកមន្ត្រីរាជការរបស់យើង ឱ្យកាន់តែមានលក្ខណសម្បត្តិល្អប្រពៃនិងយល់ច្បាស់អំពី

កាតព្វកិច្ចរបស់ខ្លួនដែលត្រូវបំពេញជូនប្រជាជន និង មាតុភូមិជាទីស្នេហារបស់យើងទាំងអស់គ្នា ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៩



សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

និងជាប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

# មាតិកា


~ **អារម្ភកថា**........................................ i

~ **សេចក្តីផ្តើម**........................................ ១

**១.~ឆន្ទៈម្ចាស់ការ**........................................ ៨

១.១-ទឹកចិត្តស្រឡាញ់ការងារ........................ ៩

១.២-ការមានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត.......... ១០

១.៣-ការបំពេញកាតព្វកិច្ចក្នុងស្មារតីជាក្រុម..... ១១

១.៤-ស្មារតីឈ្នះឈ្នះលើការងារ.................. ១២

១.៥-ការជម្នះឧបសគ្គ.................................. ១៣

**២.~ភក្តីភាព**................................................ ១៥

២.១-ការយល់ដឹងអំពីសភាពការណ៍................ ១៦

២.២-ភក្តីភាពចំពោះស្ថាប័ន.......................... ១៧

២.៣-ភក្តីភាពចំពោះវិជ្ជាជីវៈ........................ ១៧

២.៤-ភក្តីភាពចំពោះប្រជាពលរដ្ឋដែល
ជាអ្នកប្រើប្រាស់សេវា.......................... ១៩
**៣_មនសិការវិជ្ជាជីវ:**............................ ២១
**៤_វប្បធម៌សេវាសាធារណ:**.................... ២៩
៤.១-ការផ្លាស់ប្តូរឥរិយាបថ......................... ៣២
៤.២-អ្នកផ្តល់សេវា....................................... ៣៣
៤.៣-អ្នកប្រឹក្សាយោបល់.............................. ៣៤
៤.៤-ការសម្របសម្រួល............................... ៣៥



# សេចក្តីផ្តើម

សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺជាបុរេលក្ខខណ្ឌ និងជាធាតុដ៏សំខាន់មិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ប្រទេសកម្ពុជាយើងមានសុខសន្តិភាពពេញបរិបូរណ៌ ម្ចាស់ការគ្រប់គ្រងបាននូវស្ថិរភាពនយោបាយ និងជំរុញបាននូវល្បឿននៃការអភិវឌ្ឍប្រកបដោយក្តីសង្ឃឹមទៅអនាគត គឺអាស្រ័យដោយការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះ ដែលកើតឡើងពីបញ្ញាញាណដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជា

ណាចក្រកម្ពុជា។

ផ្អែកលើបុរេលក្ខខណ្ឌខាងលើនេះ យើងខិតខំកសាងបាននូវរដ្ឋបាលឯកភាពតែមួយរបស់ជាតិ និងជំរុញការធ្វើកំណែទម្រង់គ្រប់វិស័យ រហូតទទួលបានជោគជ័យដ៏ត្រចះត្រចង់ ជាបន្តបន្ទាប់ដូចជា ការធ្វើជំរឿនមន្ត្រីរាជការស៊ីវិល ប្រព័ន្ធចំណាត់ថ្នាក់និងប្រព័ន្ធលាភការថ្មី ការបង្កើតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងការពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ ការរៀបចំផែនការសកម្មភាពអភិបាលកិច្ចទី១ - ទី២ ការបើកវគ្គបណ្តុះបណ្តាលកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រប់គ្រង និងកម្មវិធីអភិវឌ្ឍសមត្ថភាពជំនាញ ការបង្កើតគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈជាដើម។ សមិទ្ធផលទាំងអស់នេះ មិនមែនកើតឡើងដោយឯកឯងនោះទេ គឺបានមកពីការចូលរួមសហការរបស់

មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ហើយយើងក៏មិនត្រូវស្កប់ស្កល់ និងមានមោទនភាពហួសហេតុពេកទៅលើសមិទ្ធផល ដែលយើងសម្រេចបានកន្លងមកនោះដែរ។ យើងត្រូវចាត់ទុកថាសមិទ្ធផលដ៏ធំធេងដែលបានមកពីកិច្ចសហការគ្នាយ៉ាងស្អិតរមួត គឺជាកម្លាំងជំរុញទឹកចិត្តយ៉ាងវិសេសវិសាលសម្រាប់យើងទាំងអស់គ្នា ដើម្បីបន្តអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល ឱ្យទទួលបានជោគជ័យថែមទៀត។ ក្នុងគោលបំណងបម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងវិបុលភាពរបស់ប្រទេសជាតិ យើងត្រូវប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជា " **អ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាពជូនប្រជាពលរដ្ឋ** " និងផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតពីភាពជា " **អ្នកត្រួតត្រា និងអ្នកត្រូវគេ**

**ត្រួតត្រា** " ឱ្យទៅជា " **អ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវា** " ។

វត្ថុបំណងខាងលើនេះអាចសម្រេចទៅបានលុះត្រាតែមន្ត្រីរាជការគ្រប់រូបមូលគំនិត និងមូលមាត់គ្នាយកចិត្តទុកដាក់គិតគូរទៅលើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋជាធំ យល់ច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួនដែលត្រូវបំពេញដើម្បីផលប្រយោជន៍រួម និងពង្រឹងសមត្ថភាពផ្ទាល់ខ្លួនឱ្យបានរឹងមាំ ដើម្បីរួមចំណែកឱ្យបានកាន់តែសកម្មក្នុងការសម្រាលទុក្ខលំបាករបស់ប្រជាពលរដ្ឋ ក៏ដូចជាការកាត់បន្ថយភាពក្រីក្រ បានសេចក្តីថា ឥរិយាបថមន្ត្រីរាជការត្រូវមានគុណសម្បត្តិ ៤ យ៉ាងគឺៈ ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការ វិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ ។

ក្នុងគោលបំណងផ្សព្វផ្សាយដល់មន្ត្រីរាជការ

គ្រប់រូបឱ្យយល់ដឹងកាន់តែច្បាស់អំពីលក្ខណសម្បត្តិ ទាំង ៤ នៃរដ្ឋបាលសាធារណៈ សម្តេចអគ្គមហាសេនាបតីតេជោ **នាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ ឱ្យរៀបចំចងក្រង និងបោះពុម្ពកូនសៀវភៅនេះឡើង សម្រាប់ជាជំនួយស្មារតី និងជាមូលដ្ឋានកែលម្អអាកប្បកិរិយា និងឥរិយាបថរបស់មន្ត្រីរាជការឱ្យក្លាយខ្លួនពិតប្រាកដទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងគុណភាព ជូនប្រជាជនយើងដែលជាអ្នកប្រើប្រាស់សេវា។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៩



**សុខ អាន**

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

អនុប្រធានអចិន្ត្រៃយ៍នៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

# គុណសម្បត្តិ
# នៃ
# ឥរិយាបថរបស់មន្ត្រីរាជការ

ឆន្ទៈម្ចាស់ការ

ភក្តីភាព

មនសិការវិជ្ជាជីវៈ

វប្បធម៌សេវាសាធារណៈ

## ១_ឆន្ទៈម្ចាស់ការ

ឆន្ទៈម្ចាស់ការ គឺជាដំណើរការមួយដែល ជំរុញ តម្រង់ទិស និងថែរក្សានូវឥរិយាបថមនុស្ស ទៅក្នុងទិសនៃការសម្រេចគោលបំណងណាមួយ។ កត្តាមួយដែលនាំឱ្យបុគ្គល ឬក្រុម ឬអង្គភាពទទួល ជោគជ័យ គឺកត្តាឆន្ទៈបម្រើការងាររបស់បុគ្គលនោះ ឬសមាជិកនៅក្នុងក្រុម ឬអង្គភាពនោះ។ ឆន្ទៈបម្រើ ការងារនេះ ផ្តើមចេញពីមនសិការរបស់បុគ្គល ឬក្រុម មិនមែនជាកត្តាកំណត់ឬជាការចាប់បង្ខំនោះទេ ក៏ប៉ុន្តែ ជាទូទៅតម្លៃរបស់មនុស្ស គឺផ្សារភ្ជាប់ទៅនឹងការងារ និងរបៀបនៃការប្រតិបត្តិ។ ខាងក្រោមនេះជាកត្តា មួយចំនួនដែលមន្រ្តីរាជការគួរប្រតិបត្តិដើម្បីជោគជ័យ របស់អង្គភាពនិងបុគ្គលខ្លួនឯង៖

## ១.១-ទឹកចិត្តស្រឡាញ់ការងារ

មន្ត្រីរាជការ ត្រូវតែមានទឹកចិត្តស្រឡាញ់ការងារ និងស្ថាប័នរបស់ខ្លួន ពីព្រោះការងារនោះហើយជាមុខរបរពិតប្រាកដ ដែលខ្លួនបានជ្រើសរើសយក មានន័យថា មន្ត្រីរាជការត្រូវតែដឹងថាការងារជាអ្នកកំណត់អំពីជោគវាសនានិងអនាគតរបស់ខ្លួន។ ការធ្វេសប្រហែសណាមួយ ឬការមិនយកចិត្តទុកដាក់ណាមួយទៅលើការងារ មានន័យស្មើនឹងការធ្វេសប្រហែស ឬការមិនយកចិត្តទុកដាក់ទៅលើអនាគតរបស់ខ្លួនយ៉ាងដូច្នោះដែរ។ គ្រប់ថ្នាក់ដឹកនាំស្ថាប័នទាំងអស់តែងតែឱ្យតម្លៃទៅលើមន្ត្រីរាជការណាដែលមានឆន្ទៈបម្រើការងារ ទឹកចិត្តស្មោះត្រង់ ហើយខិតខំបំពេញការងារឱ្យមានប្រសិទ្ធភាពដើម្បីធ្វើឱ្យស្ថាប័នរីកចម្រើន ហើយការវិវត្តអាជីពរបស់មន្ត្រីរាជការ ក៏ផ្អែកលើការងារដែលមន្ត្រីរាជការនីមួយៗបានបំពេញផងដែរ។

## ១.២-ការមានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត

ក្រៅពីបំពេញកាតព្វកិច្ចតាមផែនការដែលអង្គភាពបានដាក់ចេញ មន្ត្រីរាជការត្រូវខិតខំសិក្សាស្វែងយល់ ត្រូវមានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត ក្នុងគោលបំណងកែលម្អសកម្មភាពការងារ សំដៅធ្វើឱ្យការងារមានប្រសិទ្ធភាព និងមានការរីកចម្រើនឆាប់រហ័ស។ ការមានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត គឺជាចក្ខុវិស័យដែលកើតឡើងនៅពេលមន្ត្រីរាជការចេះស្រឡាញ់ការងារ ចេះស្រឡាញ់វិជ្ជាជីវៈ និងមានគោលដៅច្បាស់លាស់ ចង់ឱ្យការងារទទួលជោគជ័យ ចង់ឱ្យអង្គភាពមានការរីកចម្រើន និងមានកិត្យានុភាព ជាពិសេសការរៀបចំផែនការដើម្បីអនាគតរបស់ខ្លួនផ្ទាល់ផងដែរ។

## ១.៣-ការបំពេញកាតព្វកិច្ចក្នុងស្មារតីជាក្រុម

មន្ត្រីរាជការ ចាំបាច់ត្រូវមានទស្សនៈទូលំទូលាយ និងចេះរួមសហការគ្នាបំពេញការងារក្នុងគោលដៅរួមតែមួយ គឺការធ្វើឱ្យអង្គភាពបានសម្រេចលទ្ធផលខ្ពស់។ ការធ្វើការងាររួមជាក្រុមនេះ គឺជាគោលគំនិតដ៏មានសារៈសំខាន់គ្រប់កាលៈទេសៈ ហើយគោលគំនិតនេះ ជាមូលដ្ឋាននាំដល់ការកាត់បន្ថយនូវគម្លាតរវាងថ្នាក់ធ្វើគោលនយោបាយ និងថ្នាក់អនុវត្តរវាងមន្ត្រី និងមន្ត្រី ជាពិសេសកាត់បន្ថយនូវរាល់កំហុសឆ្គងផ្សេងៗ ឬការខ្វែងគំនិតគ្នានៅក្នុងអង្គភាពដែលករណីនេះនាំឱ្យមន្ត្រីរាជការចេះគោរពស្រឡាញ់រាប់អានគ្នា រួមគ្នាទទួលខុសត្រូវ យល់អធ្យាស្រ័យគ្នាទៅវិញទៅមកជាដើម។

## ១.៤-ស្មារតីឈ្មុសឈ្មុលនឹងការងារ

មន្ត្រីរាជការ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានម៉ត់ចត់ និងដោយស្មារតីទទួលខុសត្រូវខ្ពស់នូវភារកិច្ចដែលថ្នាក់លើប្រគល់ឱ្យនិងភារកិច្ចជំនាញរបស់ខ្លួន។ ក្រោយពីបានបំពេញភារកិច្ចទាំងនោះដោយជោគជ័យរួចហើយ មន្ត្រីរាជការមិនត្រូវទុកពេលវេលាឱ្យទំនេរចោលឥតប្រយោជន៍នោះទេ គឺត្រូវមានគំនិតចង់ចេះចង់ដឹងថែមទៀត ដោយស្វះស្វែងរកការងារបន្ថែមដោយខ្លួនឯង មិនត្រូវអង្គុយចាំឱ្យការងាររត់មករកយើងនោះទេ។ នេះគឺជាការបណ្តុះនូវមនសិការការងារ និងស្មារតីភ្ញាក់រឭករបស់មន្ត្រីម្នាក់ៗគ្រប់ពេលវេលា។ មន្ត្រីរាជការ មិនត្រូវខ្លាចនឿយហត់នៅពេលមានការងារច្រើនពេកឬភ័យបារម្ភចំពោះការងារលំបាកឡើយ គឺត្រូវតែមានភាពអំណត់

ព្យាយាមជានិច្ច ដើម្បីសម្រេចជោគជ័យក្នុងការងារ។ ភាពខ្ជីខ្ជា ធ្វើឱ្យរួចតែពីដៃ ដោយមិនគិតអំពីលទ្ធផលការងារ មិនគិតពីផលប្រយោជន៍រួម គឺជាប្រការដែលត្រូវចៀសវាងឱ្យខាងតែបាន។ ភាពមានការងារធ្វើជាប្រចាំ នឹងធ្វើឱ្យមន្ត្រីរាជការពង្រឹងបាននូវសមត្ថភាពរបស់ខ្លួន ព្រមទាំងទទួលបាននូវបទពិសោធ ចំណេះដឹង ចំណេះធ្វើ និងជំនឿទុកចិត្តពីថ្នាក់ដឹកនាំ ថែមទៀតផង។

## ១.៥-ការជម្នះឧបសគ្គ

ជាទូទៅ គ្មានការងារណាដែលមិនជួបឧបសគ្គនោះទេ ប៉ុន្តែឧបសគ្គមិនមែនជារបាំងដែលមករាំងស្ទះការងាររបស់យើងគ្រប់ពេលនោះដែរ។ ម្យ៉ាងទៀត គ្រប់ឧបសគ្គទាំងអស់ មិនមែនសុទ្ធតែអាក្រក់នោះទេ ឧបសគ្គខ្លះផ្តល់នូវបទពិសោធដ៏កម្រសម្រាប់យើង

ម្នាក់ៗផងដែរ។ ដូច្នេះមន្ត្រីរាជការទាំងអស់ត្រូវតែប្រកាន់ខ្ជាប់នូវស្មារតីទទួលខុសត្រូវខ្ពស់ ហើយត្រៀមខ្លួនគ្រប់ពេលដើម្បីកាត់បន្ថយបញ្ហា និងជម្ងឺឧបសគ្គដែលកើតមាន មិនត្រូវភ័យខ្លាច រួញរា និងជាពិសេសមិនត្រូវបោះបង់ចោលភារកិច្ចរបស់ខ្លួនជាដាច់ខាត។

ក្រៅពីចំណុចទាំងឡាយដូចបានរៀបរាប់ខាងលើនៅមានចំណុចសំខាន់ៗមួយចំនួនទៀតដែលមន្ត្រីរាជការត្រូវតែប្រកាន់ខ្ជាប់ដូចជា: ទីមួយ មានស្មារតីតស៊ូអំណត់ព្យាយាម និងមិនរួញរាចំពោះភារកិច្ច ទីពីរ មានការគិតទុកជាមុន ទីបី មានការចែករំលែកបទពិសោធ និងចំណេះដឹងដល់អ្នករួមការងារ ទីបួន មានការឈឺឆ្អាលចេះជួយអ្នកដទៃ ទីប្រាំ ការតាំងចិត្តមកធ្វើការពិតប្រាកដ មិនមែនគ្រាន់តែមកកន្លែងធ្វើការហើយមិនធ្វើការ ទីប្រាំមួយ មានការលះបង់

ខ្ពស់ដើម្បីបុព្វហេតុរួម ទីប្រាំពីរចាត់ទុកខ្លួនជាអ្នកបម្រើប្រជាពលរដ្ឋ និងទីប្រាំបី គោរពឋានានុក្រម និងមានគណនេយ្យភាពជាដើម ។ល ។

## ២_ភក្តីភាព

ភក្តីភាពគឺជាសេចក្តីត្រូវការដែលមនុស្សក្នុងសង្គមអរិយធម៌ត្រូវតែប្រកាន់ខ្ជាប់ ដើម្បីលើកតម្កើងកិត្តិយស និងសេចក្តីថ្លៃថ្នូរ ទាំងក្នុងនាមបុគ្គលនិងក្នុងនាមស្ថាប័ន ដែលខ្លួនកំពុងបម្រើការងារផង ។ ភក្តីភាពនេះ ទោះបីជាពុំមានចែងនៅក្នុងច្បាប់ឬបញ្ញត្តិផ្សេងៗ ឬក៏ជាកាតព្វកិច្ចក៏ដោយ ក៏នេះគឺជាសុជីវធម៌ និងសីលធម៌ដែលជាគុណតម្លៃខាងចរិយាធម៌របស់មនុស្ស ។ ភក្តីភាពនេះបង្ហាញឱ្យឃើញឡើងតាមរបៀបនៃការគិត ការប្រតិបត្តិរបស់បុគ្គលនីមួយៗ ដែលសកម្មភាពទាំងនេះស្តែងចេញនូវសេចក្តីថ្លៃថ្នូរ ការទទួលខុសត្រូវ និងផលប្រយោជន៍របស់អង្គភាព និង

ផលប្រយោជន៍សាធារណៈ។

មន្ត្រីរាជការដែលប្រកបដោយមនសិការត្រូវប្រកាន់ខ្ជាប់នូវភក្ដីភាពតាមរយៈសកម្មភាពមួយចំនួន ដូចខាងក្រោមៈ

## ២.១-ការយល់ដឹងអំពីសភាពការណ៍

មន្ត្រីរាជការត្រូវមានទស្សនៈទូលំទូលាយដែលក្រៅពីចំណេះដឹងជាមូលដ្ឋានរបស់ខ្លួន មន្ត្រីរាជការគ្រប់រូបចាំបាច់ត្រូវធ្វើការសិក្សា និងស្វែងយល់បន្ថែមនូវការវិវត្តនៃសភាពការណ៍ជុំវិញខ្លួន សភាពការណ៍វិវត្តក្នុងសង្គម និងពិភពលោក ជាពិសេសការវិវត្តរីកចម្រើនរបស់រាជរដ្ឋាភិបាលដែលខ្លួនកំពុងបំពេញការងារ។ ការស្វែងយល់ពីសភាពការណ៍ គឺជាការបង្កើននូវជំនឿស្មារតីទទួលខុសត្រូវ ចំណេះដឹង ការផ្ដួចផ្ដើមគំនិត ដើម្បីជំរុញការប្រតិបត្តិការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាពនិងមានការរីកចម្រើនដល់

ក្រសួងស្ថាប័នរបស់ខ្លួននិងធ្វើឱ្យមានការឯកភាពជាធ្លុងមួយនៅក្នុងក្រសួង ស្ថាប័នទៀតផង។

## ២.២-ភក្តីភាពចំពោះស្ថាប័ន

មន្ត្រីរាជការត្រូវមានភាពស្មោះត្រង់ ឬភក្តីភាពជានិច្ចចំពោះប្រទេសជាតិ ចំពោះគោលនយោបាយនិងមាគ៌ាដឹកនាំរបស់រាជរដ្ឋាភិបាល ចំពោះផលប្រយោជន៍រដ្ឋ ចំពោះថ្នាក់ដឹកនាំ និងចំពោះក្រសួងស្ថាប័នរបស់ខ្លួន ហើយភក្តីភាពនេះ ជាមូលដ្ឋានចាំបាច់ដែលមន្ត្រីគ្រប់រូបត្រូវប្រកាន់ខ្ជាប់គ្រប់កាលៈទេសៈនិងគ្រប់ទីកន្លែងដែលខ្លួនបំពេញការងារ អាចនិយាយបានថាជាគុណធម៌ដែលមន្ត្រីរាជការគ្រប់រូបត្រូវតែប្រកាន់ខ្ជាប់។

## ២.៣-ភក្តីភាពចំពោះវិជ្ជាជីវៈ

មន្ត្រីរាជការគ្រប់រូប ត្រូវបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ មានមនសិការ

វិជ្ជាជីវៈខ្ពស់ក្នុងគោលដៅធ្វើឱ្យអង្គភាពរីកចម្រើន។ មន្ត្រីរាជការទាំងអស់ត្រូវបង្ហាញឱ្យឃើញថា ខ្លួនមានសមត្ថភាពក្នុងវិជ្ជាជីវៈជាដរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន។ ក្នុងន័យនេះ មន្ត្រីរាជការគ្រប់រូបមិនត្រូវធ្វើឱ្យខូចឬអាប់ឱនកិត្យានុភាពរបស់រដ្ឋបាលសាធារណៈ គឺរក្សានូវពាក្យសំដីដែលនិយាយចេញទៅឬសរសេរចេញទៅដោយប្រុងប្រយ័ត្ន មិននិយាយអ្វីដែលប៉ះពាល់ដល់កិត្តិយស កិត្យានុភាពរបស់ក្រសួងស្ថាប័ន អង្គភាព ឬសមត្ថកិច្ចថ្នាក់ដឹកនាំរបស់ខ្លួន។ មន្ត្រីរាជការ ត្រូវគោរពការសម្ងាត់វិជ្ជាជីវៈ ព្រោះថាការធ្វើឱ្យបែកធ្លាយនូវការសម្ងាត់វិជ្ជាជីវៈ នឹងនាំឱ្យបាត់បង់នូវភាពរលូននៅក្នុងដំណើរការការងារ ឬភាពចលាចលក្នុងសង្គម ឬក៏អាចបណ្តាលឱ្យមានការគាំងស្ទះការងារ ដែលអាចប៉ះពាល់ដល់សុវត្ថិភាព

រដ្ឋបាលផងដែរ។ មន្ត្រីរាជការ ធ្វើការនៅកន្លែងណា មិនត្រូវនិយាយអាក្រក់ពីអ្នកដឹកនាំកន្លែងនោះឡើយ តែត្រូវមានភារកិច្ច កាតព្វកិច្ចរក្សាការពារកិត្តិសព្ទ របស់ថ្នាក់ដឹកនាំឬអង្គភាពនៅទីនោះ។ ម្យ៉ាងទៀត មន្ត្រីរាជការទាំងអស់ ត្រូវធ្វើយ៉ាងណាកុំឱ្យបែកធ្លាយ ចេញទៅក្រៅនូវរាល់ហេតុការណ៍ គ្រប់ព័ត៌មាន ឬ ឯកសារទាំងឡាយណាដែលខ្លួនបានដឹង បានឮនៅ ក្នុងការងារ ឬក្នុងការបំពេញការងារប្រសិនបើគ្មានការ អនុញ្ញាតពីថ្នាក់លើរបស់ខ្លួន ឬក្រៅពីសមត្ថកិច្ចរបស់ ខ្លួន ឬគ្មានការកំណត់ដោយច្បាប់។

## ២.៤-ភក្ដីភាពចំពោះប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវា

មន្ត្រីរាជការគ្រប់រូបត្រូវរ៉ាប់រងការងារ ឬ សេវាទាំងឡាយ ដែលអង្គភាពឬថ្នាក់ដឹកនាំប្រគល់ជូន ឬចាត់តាំងឱ្យអនុវត្ត ព្រោះការងារដែលមន្ត្រីរាជការ

ទទួលអនុវត្ត គឺជាការងាររដ្ឋ ការងារសាធារណៈ ដែលត្រូវបានបែងចែក និងកំណត់ច្បាស់លាស់ចំពោះមន្ត្រីម្នាក់ៗ ហើយតម្រូវការចាំបាច់ឱ្យមន្ត្រីនោះមានវត្តមានជាប្រចាំដើម្បីបំពេញការងារនោះដែលជាតំណាងអំណាចសាធារណៈ។ ក្រៅពីបំពេញកាតព្វកិច្ចក្នុងក្របខណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន មន្ត្រីរាជការទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវវប្បធម៌ "អ្នកផ្ដល់សេវា និងអ្នកប្រើប្រាស់សេវា" ពីព្រោះប្រជាពលរដ្ឋគឺជាអតិថិជនជាប្រចាំ ដែលផ្សារភ្ជាប់ទៅនឹងសកម្មភាពការងាររបស់មន្ត្រីរាជការគ្រប់រូប ទោះដោយចំពោះឬដោយមិនចំពោះក្ដី។ មន្ត្រីរាជការគ្រប់រូបត្រូវយកចិត្តទុកដាក់ចំពោះការងាររបស់ខ្លួន និងផ្ដល់អាទិភាពទៅលើសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ ដែលជាអ្នកប្រើប្រាស់សេវា តាមរយៈការផ្ដល់នូវជំនឿទុកចិត្ត

ប្រសិទ្ធភាពការងារ តម្លាភាព និងការធ្វើទំនាក់ទំនងប្រកបដោយភាតរភាព។

### ៣_មនសិការវិជ្ជាជីវៈ

មន្ត្រីរាជការទាំងអស់ សុទ្ធតែស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់និងបទប្បញ្ញត្តិផ្សេងៗរៀងៗខ្លួន ទោះជានៅបម្រើការងារក្នុងវិស័យណាក្តី (ឧទាហរណ៍ មន្ត្រីរាជការស៊ីវិលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌនីមួយៗ) ។ ថែមពីលើនេះទៀត នៅក្នុងវិជ្ជាជីវៈរបស់ខ្លួន មន្ត្រីរាជការក៏ត្រូវមានកាតព្វកិច្ចគោរពច្បាប់ដទៃទៀតរបស់រដ្ឋផងដែរ ក្នុងនាមខ្លួនជាពលរដ្ឋម្នាក់។

ដើម្បីបំពេញវិជ្ជាជីវៈឱ្យបានល្អ មន្ត្រីរាជការគ្រប់រូបត្រូវតែអនុវត្តឱ្យបានម៉ឺងម៉ាត់នូវកាតព្វកិច្ច

នានាដែលបានកំណត់នៅក្នុងច្បាប់និងបទប្បញ្ញត្តិផ្សេងៗ ប៉ុន្តែកាតព្វកិច្ចមួយចំនួនទៀត ដូចជាកាតព្វកិច្ចផ្អែកសីលធម៌ជាដើម ពិតមែនតែមិនមានការកំណត់នៅក្នុងច្បាប់ឬបទប្បញ្ញត្តិផ្សេងៗ ក៏មន្ត្រីរាជការត្រូវតែយកចិត្តទុកដាក់គិតគូរផងដែរ ដោយតម្រូវឱ្យលើកកម្ពស់មនសិការវិជ្ជាជីវៈ មនសិការស្នេហាជាតិ មាតុភូមិជាដើម ។

ការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈនិងការទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួន គឺជាកាតព្វកិច្ចសំខាន់ដែលមន្ត្រីរាជការគ្រប់រូបត្រូវបំពេញឱ្យបានដើម្បីប្រសិទ្ធភាពការងារ ។ សកម្មភាពសំខាន់ៗមួយចំនួនដែលមន្ត្រីរាជការប្រកបដោយមនសិការវិជ្ជាជីវៈត្រូវប្រតិបត្តិ មានដូចខាងក្រោមៈ

៣.១- មន្ត្រីរាជការត្រូវប្រឹងប្រែងឱ្យអស់លទ្ធភាព

ដើម្បីបំពេញការងារជាមួយនឹងមធ្យោបាយ ដែលមាន សំដៅធ្វើឱ្យមានការរីកចម្រើននិងមានប្រសិទ្ធភាព ។

៣.២- មន្ត្រីរាជការត្រូវយកចិត្តទុកដាក់ឱ្យបានច្បាស់លាស់ក្នុងការបំពេញការងារនិងមានមនសិការធ្វើការងារដើម្បីសម្រេចលទ្ធផល ស្របតាមផែនការសកម្មភាពដែលបានគ្រោងទុកឬសកម្មភាពការងារដែលថ្នាក់លើប្រគល់ឱ្យ ។

៣.៣- មន្ត្រីរាជការត្រូវប្តេជ្ញាចិត្តធ្វើការអភិវឌ្ឍខ្លួននិងប្រើប្រាស់សមត្ថភាព ចំណេះដឹង ជំនាញ ភាពប៉ិនប្រសប់ និងចរិតលក្ខណៈរបស់ខ្លួនឱ្យបានជាអតិបរមា និងប្រកបដោយសេចក្តីថ្លៃថ្នូរ ។

៣.៤- មន្ត្រីរាជការត្រូវស្វិតស្វាញក្នុងការធ្វើការងារជាមួយមន្ត្រីរាជការដទៃទៀតនិងត្រូវសម្រេច

លទ្ធផលការងារជាមួយគ្នានោះឱ្យបានត្រឹមត្រូវ ។

៣.៥- មន្ត្រីរាជការត្រូវហ៊ានលះបង់កម្លាំងកាយនិងចិត្តចំពោះការងារដែលមានជំនាញខ្ពស់និងប្តេជ្ញាចិត្តបម្រើផលប្រយោជន៍សាធារណៈ ។

៣.៦- មន្ត្រីរាជការចាំបាច់ត្រូវបង្កើនសមត្ថភាពជំនាញឯកទេស ចំណេះដឹង និងបទពិសោធរបស់ខ្លួនដើម្បីអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនឱ្យទាន់សភាពការណ៍ជារៀងរហូត ។

៣.៧- មន្ត្រីរាជការមិនអាចយកពេលវេលាបំពេញការងារទៅប្រកបវិជ្ជាជីវៈឯកជនបន្ថែមដើម្បីយកកម្រៃបានទេ ទោះជាក្នុងប្រភេទណាក៏ដោយគឺអាចធ្វើបានតែក្នុងករណីដែលច្បាប់អនុញ្ញាតប៉ុណ្ណោះ ។

៣.៨- មន្ត្រីរាជការមិនអាចទទួលយកដោយផ្ទាល់ឬ

ដោយប្រយោលតាមរយៈតំណាងរបស់ខ្លួននូវផលប្រយោជន៍នានា ពីនរណាមួយ ឬពីសហគ្រាសមួយដែលស្ថិតនៅក្រោមការត្រួតពិនិត្យរដ្ឋបាលរបស់អង្គភាពដែលខ្លួនធ្វើការឬអង្គភាពដែលខ្លួនមានទំនាក់ទំនងជាមួយនោះបានទេ បើផលប្រយោជន៍នោះធ្វើឱ្យប៉ះពាល់ដល់អព្យាក្រឹតភាពរបស់មន្ត្រីរាជការ ។

៣.៩- មន្ត្រីរាជការត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ តាមគោលការណ៍និងស្មារតីដូចមានចែងក្នុងច្បាប់ជាធរមាន ។ ឧទាហរណ៍ គ្រូពេទ្យមិនត្រូវយកស្ថានភាពរបស់អ្នកជំងឺម្នាក់ ទៅលាតត្រដាងប្រាប់អ្នកដទៃ គណៈមេប្រយោគមិនត្រូវធ្វើឱ្យបែកធ្លាយនូវវិញ្ញាសាសម្រាប់ការប្រឡងឡើយ ។ល ។

៣.១០- មន្ត្រីរាជការត្រូវប្រកាន់ខ្ជាប់នូវ**កាតព្វកិច្ច**

**លក្ខណាការណ៍** មានន័យថា មិននិយាយ ឬសរសេរ ពីអ្វីដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និង កិត្យានុភាពរបស់អង្គភាព ឬសមត្ថកិច្ច ថ្នាក់ដឹកនាំរបស់ខ្លួន។

៣.១១- មន្ត្រីរាជការ ទោះជាស្ថិតក្នុងតួនាទី ឬឋានានុក្រម ណាក៏ដោយត្រូវតែទទួលខុសត្រូវលើការប្រតិបត្តិ របស់ខ្លួន ចំពោះភារកិច្ចដែលបានប្រគល់ឱ្យ។

៣.១២- មន្ត្រីរាជការមានកាតព្វកិច្ចរ៉ាប់រងសេវារបស់ខ្លួន ទៅតាមការចាត់តាំងរបស់ថ្នាក់លើ ចៀសវាង ការចន្លោះប្រហោងនៅក្នុងការបំពេញមុខងារ របស់ខ្លួន ដែលនាំឱ្យមានការរំខានគ្នាំគ្គងនៅក្នុងវិជ្ជា ជីវៈជាមន្ត្រីរាជការបម្រើរដ្ឋ។

៣.១៣- មន្ត្រីរាជការមានកាតព្វកិច្ចគោរពវិន័យការងារ ម៉ោងពេលធ្វើការនិងបទបញ្ជាផ្ទៃក្នុងរបស់អង្គ

ភាពឱ្យបានម៉ឺងម៉ាត់ ដើម្បីធានានិរន្តរភាពនៃសេវាសាធារណៈ។ ការខកខាន ព្រងើយកន្តើយ សោះអង្គើយមិនបានបំពេញកាតព្វកិច្ចនេះនឹងនាំមកនូវផលវិបាកធ្ងន់ធ្ងរដល់អ្នកត្រូវទទួលអត្ថប្រយោជន៍ពីសេវាសាធារណៈ និងកិត្យានុភាពនៃរដ្ឋបាលសាធារណៈផងដែរ។ ក៏ប៉ុន្តែចំពោះការងារចាំបាច់បន្ទាន់ និងការងារជំនាញខ្លះទាមទារឱ្យមន្ត្រីយើងមានឆន្ទៈលះបង់ខ្ពស់ធ្វើការងារលើសម៉ោងកំណត់ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែង។ ឧទាហរណ៍ការងាររដ្ឋបាលខ្លះមានការប្រញាប់ខ្លាំងដែលតម្រូវឱ្យធ្វើឱ្យចប់ក្នុងពេលវេលាមួយកំណត់គឺត្រូវតែធ្វើបង្ហើយ មិនអាចពន្យារពេលបាន។ គ្រូពេទ្យវះកាត់ដែលកំពុងដំណើរការវះកាត់អ្នក

ជំងឺមិនអាចទុកចោលសិន ហើយបន្តការវះកាត់នៅពេលក្រោយទៀតបានទេ។

៣.១៤- មន្ត្រីរាជការទាំងអស់ ត្រូវតែគោរពបញ្ជារបស់ថ្នាក់លើដែលបានចាត់ឱ្យទៅបម្រើការងារ ទោះជានៅទីណាក្តី ។ មន្ត្រីរាជការមិនត្រូវធ្វើការឱ្យរួចពីដៃ ខ្វះការទទួលខុសត្រូវនិងមិនគិតអំពីប្រសិទ្ធភាពការងារ និងផលប្រយោជន៏សាធារណៈនោះឡើយ ។

៣.១៥- រដ្ឋបាលសាធារណៈ គឺជារដ្ឋបាលឋានានុក្រមតម្រូវឱ្យថ្នាក់ក្រោមគោរពថ្នាក់លើជាហូរហែតាមលំដាប់ថ្នាក់។ ក្នុងន័យនេះ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងដើម្បីធានាបាននូវការទទួលខុសត្រូវខ្ពស់ក្នុងការងារ រាល់ការចាត់តាំង ការដាក់ចុះនូវបទបញ្ជាត្រូវតែអនុវត្ត

ឱ្យបានត្រឹមត្រូវទៅតាមនីតិវិធី និងតាមគោលការណ៍ គឺត្រូវគោរពឱ្យបាននូវគោលការណ៍នីតិរដ្ឋ។

## ៤.ទប្បធម៌សេវាសាធារណៈ

សេវាសាធារណៈ គឺរាល់សកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋ ដែលបំពេញការងារតាមដែនកំណត់របស់ខ្លួន ឬផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិនិងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។ សេវាសាធារណៈដូចបានកំណត់ន័យខាងលើ ត្រូវបានចងក្រងនិងប្រមូលផ្តុំជា៧ប្រភេទធំៗ ដូចមានកំណត់នៅក្នុងគោលនយោបាយស្តីពីការផ្តល់

សេវាសាធារណៈ ទៅតាមវិស័យនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននីមួយៗ ដូចខាងក្រោមៈ

- ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ
- ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម
- ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល
- ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូចនិងមធ្យម បរិស្ថានវិនិយោគនិងការចូលរួមរបស់ផ្នែកឯកជន ក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ
- ចង្កោមសេវាសង្គមកិច្ច វប្បធម៌និងកិច្ចការនារី
- ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត
- ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូលនិង

ការធ្វើវិចារណកម្មចំណាយនិងការបើកផ្តល់។

ការផ្តល់សេវាបានល្អ មានប្រសិទ្ធភាពនិងគុណភាព គឺជាការចូលរួមយ៉ាងសកម្មក្នុងការលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានប្រសើរឡើង ដែលជាគោលបំណងរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ ដើម្បីសម្រេចបានគោលបំណងនេះ មន្ត្រីរាជការគ្រប់រូបត្រូវតែបណ្តុះនូវវប្បធម៌សេវាសាធារណៈ ឱ្យបានដក់ជាប់ក្នុងផ្នត់គំនិតរបស់ខ្លួន ដើម្បីក្លាយទៅជាទម្លាប់ដូចការអនុវត្តនៅក្នុងវិស័យឯកជន។

នៅក្នុងចំណោមមន្ត្រីរាជការ វប្បធម៌សេវាសាធារណៈអាចមានការពិបាកយល់ ក៏ប៉ុន្តែនៅក្នុងទស្សនវិស័យរបស់ឯកជនវិញ គឺមានភាពសាមញ្ញបំផុត

ដោយគេចាត់ទុកថា "អតិថិជនជាស្តេច" ហើយ "ការពេញចិត្តរបស់អតិថិជន គឺជាភារកិច្ចរបស់គេ"។ ឆ្លងតាមបរិបទនេះហើយ ដែលមន្ត្រីរាជការនៅក្នុងវិស័យរដ្ឋបាលសាធារណៈរបស់រដ្ឋ ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងកែប្រែរបៀបរបបនៃការបំពេញការងារក្នុងគោលបំណង **បម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង** តាមរយៈការប្រែក្លាយខ្លួនឱ្យទៅជា "**អ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព**" ។

វប្បធម៌សេវាសាធារណៈ ផ្តោតលើគោលការណ៍មួយចំនួនដូចខាងក្រោម៖

## ៤.១-ការផ្លាស់ប្តូរឥរិយាបថ

នៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋ គឺមានឋានានុក្រម ប៉ុន្តែរដ្ឋាភិបាលជាមួយប្រជាពលរដ្ឋ ពុំមាន

ឋានានុក្រមទេ។ ហេតុនេះហើយ មន្ត្រីរាជការចាំបាច់ត្រូវកែប្រែឥរិយាបថនិងរបៀបរបបនៃការធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវាប្រកបដោយសេចក្តីថ្លៃថ្នូរ មានភាតរភាព និងការទទួលខុសត្រូវខ្ពស់។ ការផ្លាស់ប្តូរឥរិយាបថគឺជាកត្តាចាំបាច់ដើម្បីឱ្យមន្ត្រីរាជការគ្រប់រូបបំពេញតួនាទីជាអ្នកបម្រើដ៏ស្មោះត្រង់របស់ប្រជាពលរដ្ឋ មានន័យថាត្រូវផ្លាស់ប្តូរពីភាពជា "អ្នកត្រួតត្រាគេ" ទៅជា "អ្នកផ្តល់សេវា" វិញ។ ការងារនេះជាការលំបាកក៏ពិតមែន ក៏ប៉ុន្តែមិនហួសកម្រិតដែលយើងមិនអាចធ្វើបាននោះទេ ឱ្យតែយើងខិតខំប្រឹងប្រែងធ្វើទាំងអស់គ្នា។

## ៤.២-អ្នកផ្តល់សេវា

ការធ្វើទំនាក់ទំនងនិងរបៀបរបបធ្វើការងារត្រូវផ្តោតទៅលើសេចក្តីត្រូវការជាក់ស្តែងរបស់អ្នកប្រើ

ប្រាស់សេវា។ សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវានោះហើយ គឺជាអាទិភាពនិងជាកាតព្វកិច្ចដែលមន្ត្រីរាជការ (អ្នកផ្តល់សេវា) ត្រូវឆ្លើយតបប្រកបដោយមនសិការវិជ្ជាជីវៈនិងសេចក្តីថ្លៃថ្នូរ។ មន្ត្រីរាជការ មិនត្រូវប្រើប្រាស់តួនាទីនិងមុខតំណែងរបស់ខ្លួនធ្វើឱ្យប្រជាពលរដ្ឋមានការលំបាក ឬមានការភ័យខ្លាចទេ ប៉ុន្តែផ្ទុយទៅវិញ ត្រូវផ្តល់នូវជំនឿទុកចិត្ត បំបាត់នូវភាពភ័យខ្លាច ផ្តល់នូវភាពកក់ក្តៅ រាក់ទាក់ ការគោរពនិងធ្វើឱ្យប្រជាពលរដ្ឋពេញចិត្តចំពោះសកម្មភាពការងារនិងអត្តចរិករបស់មន្ត្រីរាជការឬអង្គភាពដែលជាអ្នកផ្តល់សេវា។

## ៤.៣-អ្នកប្រឹក្សាយោបល់

ត្រូវយកចិត្តទុកដាក់ផ្តល់ព័ត៌មាននិងពន្យល់ឱ្យបានច្បាស់ដល់ប្រជាពលរដ្ឋ អំពីនីតិវិធី របៀបរបប

និងបែបបទផ្សេងៗនៃការផ្តល់សេវាសាធារណៈ។ សំណួររបស់ប្រជាពលរដ្ឋ ត្រូវតែមានចម្លើយនិងមិនត្រូវបង្ហាញនូវអាកប្បកិរិយាធុញទ្រាន់ ក្រអឺតក្រទម រើសអើងរវាងអ្នកតូចនិងអ្នកធំ រវាងអ្នកក្រនិងអ្នកមាន អ្នកស្រែនិងអ្នកក្រុងឡើយ ពីព្រោះគ្រប់សំណួរឬចម្ងល់ទាំងអស់ បង្ហាញឱ្យឃើញនូវសេចក្តីត្រូវការ និងការចង់ចេះចង់ដឹងរបស់អ្នកប្រើប្រាស់សេវា ហើយទាំងអស់នេះមានសារៈសំខាន់ចំពោះការប្រតិបត្តិការងាររបស់យើងផ្ទាល់ និងធ្វើការកែលម្អ សំដៅឱ្យសេវាដែលបានផ្តល់ឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់។

## ៤.៤-ការសម្របសម្រួល

យន្តការសម្របសម្រួល មានសារៈសំខាន់ទៅលើដំណើរការនៃការផ្តល់សេវានិងការមកទទួលយកសេវាទៅប្រើប្រាស់ ពីព្រោះវានាំមកនូវការកាត់

បន្ថយគម្លាតរវាងអ្នកផ្តល់សេវានិងអ្នកប្រើប្រាស់សេវា រវាងការយល់ច្រឡំ ឬការខ្វែងគំនិតគ្នា ។ល។ ជាពិសេស ធ្វើឱ្យនីតិវិធីនៃការផ្តល់សេវាមានភាពសាមញ្ញ ខ្លី និង ទាន់ពេលវេលា និងមានភាពរលូននៅក្នុងទម្រង់ការងារទាំងអស់ ។

ដោយឡែក នៅក្នុងវិស័យផ្សេងៗដូចជា រដ្ឋបាលធុរកិច្ច សុខាភិបាលជាដើម គេបានលើកឡើងនូវពាក្យស្លោកមួយចំនួនដែលមានខ្លឹមសារមុតស្រួច ដើម្បីទាក់ទាញការចាប់អារម្មណ៍របស់អ្នកប្រើប្រាស់ ទៅលើរបៀបរបបនៃការផ្តល់សេវាក្នុងវិស័យរបស់គេ ដូចជា:

- " អតិថិជន គឺជាស្តេច "

- " ការពេញចិត្តរបស់អស់លោកអតិថិជន គឺជាកាតព្វកិច្ចរបស់យើងខ្ញុំជាធុរជននិងជាអ្នកផ្តល់សេវា "

- " អ្នកជំងឺ គឺជាម្ចាស់ "។

គុណសម្បត្តិទាំង៤យ៉ាងដូចបានរៀបរាប់ខាងលើនេះ គឺជាការលើកបង្ហាញនូវចំណុចសំខាន់ៗមួយចំនួន សម្រាប់ជាជំនួយដល់មន្ត្រីរាជការក្នុងការប្រតិបត្តិការងារ និងការផ្លាស់ប្តូរឥរិយាបថការងាររបស់ខ្លួន។ មន្ត្រីរាជការដែលបំពេញបាននូវគុណសម្បត្តិទាំង៤ យ៉ាងនេះ មិនត្រឹមតែធ្វើឱ្យប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវាមានការពេញចិត្តពេញថ្លើមប៉ុណ្ណោះទេ ប៉ុន្តែបានរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឱ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលផង ពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អក្នុងរដ្ឋបាលសាធារណៈផង និងលើកស្ទួយកិត្តិយសអង្គភាព ព្រមទាំងសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនរបស់មន្ត្រីរាជការម្នាក់ៗផងដែរ។

# កំណែទម្រង់រដ្ឋបាល

## គោលបំណង:

បម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង ដើម្បី

សុខុមាលភាពរបស់ប្រជាពលរដ្ឋ

និងវិបុលភាពប្រទេសជាតិ

## គោលដៅ:

រដ្ឋបាលសាធារណៈក្លាយជាអ្នកផ្តល់សេវាដ៏ស័ក្តិសិទ្ធ តាមរយៈ

**ការធ្វើឱ្យរដ្ឋបាលសាធារណៈ កាន់តែមាន**

តម្លាភាព ភាពឆ្លើយតប ប្រសិទ្ធភាព

**និងការលើកកម្ពស់**

ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ

វប្បធម៌សេវាសាធារណៈ

# កំណែទម្រង់រដ្ឋបាល

**គោលបំណង:**

បម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងវិបុលភាពប្រទេសជាតិយើង

**គោលដៅ:**

រដ្ឋបាលសាធារណៈក្លាយជាអ្នកផ្តល់សេវាដ៏ស័ក្តិសិទ្ធ តាមរយៈ

**ការធ្វើឱ្យរដ្ឋបាលសាធារណៈ កាន់តែមាន**

- តម្លាភាព
- ភាពឆ្លើយតប
- ប្រសិទ្ធភាព

**និងការលើកកម្ពស់**

- ឆន្ទៈម្ចាស់ការ
- ភក្ដីភាព
- មនសិការវិជ្ជាជីវៈ
- វប្បធម៌សេវាសាធារណៈ